**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤១៤
ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥
**សាលដីកា**
លេខៈ៣៨
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក ............... ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .................

**តំណាងមហាអយ្យការ**

-ឯកឧត្តម ................ អគ្គជាព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៣៨(ឈ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៣ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ចម (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤៥ឆ្នាំ ជាតិខ្មែរ តំណាងដោយមេធាវី ................ មានការិយាល័យផ្ទះលេខៈ៣៧A ផ្ទះលេខ៣០០ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

និងចុងចម្លើយឈ្មោះ លណរ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៤ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ៣០៧ ក្រុមទី៦ សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ។

មានមេធាវីលោក ........... និង ............. ។

តតីយជនឈ្មោះ ឡហហ ។

មានមេធាវីលោក ..................។

**កម្មវត្ថុបណ្តឹងៈ** ប្តឹងសុំឱ្យអនុវត្តតាមកិច្ចសន្យាលក់ដី ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ លណរ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤១៩ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០១-០៤-២០០៥ របស់ដើមចោទឈ្មោះចម ប្ដឹងសុំឱ្យអនុវត្តតាមកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី៣០-០៦-១៩៩៨ ដោយសំអាងហេតុថា : កាលពីថ្ងៃទី៣០-០៦-១៩៩៨ ឈ្មោះលណារ និងឈ្មោះហជស បានលក់ដីឱ្យខ្លួនក្នុងតម្លៃ៤,៣$ x ១m នូវទំហំដី១០ហិកតា៥០អា ស្ថិតនៅមណ្ឌល៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានប័ណ្ណកម្មសិទ្ធិលេខ$A_1$៣៥៤$A_2$. $A_3$ ៣៥៦ ចុះថ្ងៃទី១៨-០២-៩៣ ហើយការទិញ-លក់ នៅពេលនោះបានកំណត់ការប្រគល់ប្រាក់ និងកក់ប្រាក់មាន០៤ដំណាក់កាលគឺ:

- លើកទី១ចំនួន១០.០០០$ ថ្ងៃទី៣០-០៦-១៩៩៨

-លើកទី២ ចំនួន១០% ថ្ងៃទី២៣-០៧-១៩៩៨

-លើកទី៣ ចំនួន២៥% ថ្ងៃទី២៣-០៨-១៩៩៨

-លើកទី៤ចំនួនជាការបង្គ្រាប់បញ្ចប់ថ្ងៃទី២៣-០៩-១៩៩៨

ក្រោយពីចុះកិច្ចសន្យារួចហើយខ្លួនបានកក់ប្រាក់មុនចំនួន១០០០០ដុល្លា ហើយនៅថ្ងៃទី២៣-០៧-១៩៩៨ បានប្រគល់ចំនួន១០% ស្មើនឹងទឹកប្រាក់៤៥.០០០ដុល្លា បន្ទាប់មកឈ្មោះលណារ និង ហជស បានបាត់ដំណឹង ឈឹងមិនដឹងទៅណាហើយការទំនាក់ទំនងក៏ពុំបាន ពេលខ្លួនទៅរកផ្ទះរបស់ឈ្មោះលណារ ឃើញបិទទ្វារ ដោយទំនាក់ទំនងជាមួយអ្នកទាំងពីរមិនបាន ហើយក៏មិនឃើញអ្នកទាំងពីរមកយកប្រាក់បន្ថែមទៀត ទើបតែនៅពេលថ្មីៗ នេះស្រាប់តែឃើញឈ្មោះលណារ មកធ្វើការផ្ទេរសិទ្ធិដីលក់ទៅឱ្យអ្នកផ្សេងទៅវិញ ។

តាមពាក្យបណ្ដឹងសុំចូលជាតតិយជន និងសុំបដិសេធដីកាលើកពាក្យបណ្ដឹងចុះថ្ងៃទី២៥-០៧-២០០៥ របស់លោកមេធាវី..................តំណាងឱ្យតតីយជនឈ្មោះឡហហ ហៅឡេ ហួអ៊ុយបញ្ជាក់ថាខ្លួនប្ដឹងសុំចូលជាតតីយជន និងសុំបដិសេធដីកាលើកពាក្យបណ្ដឹងដោយសំអាងហេតុថា កូនក្ដីខ្លួនឈ្មោះឡហហ បានប្រគល់ប្រាក់ចំនួន៤៥០០០ដុល្លា ឱ្យទៅឈ្មោះចម ដើម្បីកក់ដីចំនួន១០ ហិកតា ដែលមានប័ណ្ណកម្មសិទ្ធិលេខ$A_1$៣៥៤ $A_1$៣៥៥ ចុះថ្ងៃទី១៨-០២១៩៩៣ ។

បន្ទាប់មកឈ្មោះចម បានយកលុយនេះទៅប្រគល់ឱ្យឈ្មោះហជស និងមានសាក្សីឈ្មោះលណារបានដឹងឮផង ព្រមទាំងមានផ្ដិតមេដៃលើកិច្ចសន្យាចុះថ្ងៃទី២៣-០៧-១៩៩៨ ជាភស្តុតាងស្រាប់ ។

លុះក្រោយមកទៀតកូនក្ដីខ្លួនឈ្មោះឡហហ ហៅឡហអបានប្រគល់ប្រាក់កក់បន្ថែមចំនួន៣០០០០ដុល្លា ទៀតឱ្យទៅឈ្មោះហជស ហើយឈ្មោះនេះក៏បានចុះហត្ថលេខាទទួលប្រាក់ដូចមានក្នុងកិច្ចសន្យា ដែលបានបកប្រែជាភាសាខ្មែរ និងភាសាចិន ។ កូនក្ដីខ្លួន បានសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី១៥-០៩-១៩៩៨ ប៉ុន្តែដល់ថ្ងៃប្រគល់ប្រាក់គ្រប់ចំនួន១៥-០៩-១៩៩៨) ស្រាប់តែឈ្មោះហជស

គេចខ្លួនបាត់តែម្តង ដោយមិនទទួលខុសត្រូវឡើយ ហើយកូនក្តីខ្លួនបានស្វែងរកអាស្រ័យដ្ឋានដែលមានក្នុងកិច្ចសន្យា តែពុំឃើញមានមនុស្សទេ និងបានទូរសព្ទ័ទំនាក់ទំនងឈ្មោះហជស ម្តងថានៅប្រទេសចិន ម្តងថានៅសាំងហ្គាពួរ គឺឈ្មោះហជស មានបំណងអាក្រក់មកលើកូនក្តីខ្លួន ។

ស្រាប់តែក្រោយមកទៀតឈ្មោះលណរ មានបំណងធ្វើការផ្ទេរសិទ្ធិដីដែល លក់ឱ្យខ្លួននោះ ទៅឱ្យអ្នកផ្សេងទៀតទើបឈ្មោះចម ដាក់ពាក្យប្តឹងទៅ តុលាការក្រុងព្រះសីហនុ នៅថ្ងៃទី១០-០៤-២០០៥ និងឈ្មោះចម បានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំ ហើយតុលាការក៏បានចេញដីកាសម្រេចតាមពាក្យសុំលេខ៤៣២គរ/០២ ហាមឃាត់ការលក់-ដូរ បញ្ចាំ, ផ្ទេរសិទ្ធិ ឬ ធ្វើអំណោយនូវដីដែលមានលេខ$A_1$៣៥៤$A_4$ ៣៥៥,$A_1$៣៥៦ ចុះថ្ងៃទី១៨-០២-១៩៩៣ ជាបណ្តោះអាសន្នសិន ។ ប៉ុន្តែការសម្រេចនោះត្រូវបានលោកមេធាវី តំណាងឱ្យចុងចម្លើយឈ្មោះលណរ ប្តឹងជំទាស់ ហើយតុលាការក៏បានសម្រេចចេញដីកាកិច្ចការប្រញាប់លេខៈ៣៩២គរ/០៥ ចុះថ្ងៃទី១៩-០៥-២០០៥ តម្កល់ដីកាសម្រេចតាមពាក្យសុំលេខ៤៣២គរ/០២ ចុះថ្ងៃទី០៦-០៤-២០០៥ ទុកជាបានការពេញទាំងមូល ។

ប៉ុន្តែក្រោយពីចេញដីកាសម្រេចកិច្ចការប្រញាប់នោះមក តុលាការក្រុងព្រះសីហនុ ក៏បានចេញដីកាលើកពាក្យបណ្តឹងលេខ៤១៧គរ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ ដោយសំអាងថាៈភាគីដើមបណ្តឹងថ្លស់សិទ្ធិក្នុងការប្តឹង ទាមទារដីនោះហើយ ។

បានឃើញ ដីកាសម្រេចតាមពាក្យសុំលេខ៤៣២គរ/០២ ចុះថ្ងៃទី០៦-០៤-២០០៥ របស់តុលាការ ក្រុងព្រះសីហនុដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងសុំចុះថ្ងៃទី០៥-០៤-២០០៥ របស់លោកចម ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២- ហាមឃាត់ការផ្ទេរសិទ្ធិការលក់-ដូរ ការជួល ការបញ្ចាំ ការធ្វើអំណោយ នៅលើដីដែលមានប័ណ្ណកម្មសិទ្ធិលេខ $A_1$៣៥៤$A_4$ ៣៥៥,$A_1$៣៥៦ ចុះថ្ងៃទី១៨-០២-១៩៩៣ ដែលស្ថិតនៅក្នុងក្រុមទី ភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាបណ្តោះអាសន្នសិន ដើម្បីរង់ចាំការសម្រេចដល់អង្គសេចក្តីពីតុលាការ ។

៣ - ក្នុងការអនុវត្តដីកានេះបើមានភាគីណាមួយមិនសុខចិត្ត ភាគីនោះមានសិទ្ធិប្តឹងមកតុលាការក្រុងព្រះ សីហនុវិញ ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីដីកានេះ។

បានឃើញពាក្យបណ្តឹងទាស់ចុះថ្ងៃទី២០-០៤-២០០៥ របស់លោកមេធាវីពុធ ធាវី តំណាងឱ្យអ្នកស្រីលណរ បានប្តឹងទាស់នឹងសេចក្តីសម្រេចពីដីកាសម្រេចតាមពាក្យសុំទាំងមូល ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ៣៩២គរ/០៥ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹម សារនៃសេចក្តីសម្រេចដូចតទៅៈ

១ - ទទួលពាក្យបណ្តឹងទាស់របស់លោកពុធ ធារី មេធាវីតំណាងចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- តម្កល់ដីកាចារលើពាក្យសុំលេខ៤៣២តរ/០៥ ចុះថ្ងៃទី០៦-០៤-២០០៥ ទុកជាបានការពេញទាំងមូលដដែល ។

៣- ដីកាសម្រេចកិច្ចការប្រញាប់នេះមានប្រសិទ្ធិភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន២.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១.៨០០៛ និងរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់របស់ដើមចោទបានបង់ទុករួចហើយ ។

ដីកាសម្រេចកិច្ចការប្រញាប់នេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគួភាគីទុកសិទ្ធិប្តឹងតវ៉ាតាម កំណត់ច្បាប់

បានឃើញ ដីកាលើកពាក្យបណ្តឹងលេខ៤១៧ត.រ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការក្រុងព្រះ សីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

លើកចោលនូវពាក្យបណ្តឹងរបស់ដើមចោទឈ្មោះចម ចុះថ្ងៃទី០១-០៤-២០០៥ ដោយដើមបណ្តឹង បានថ្លស់សិទ្ធិក្នុងការប្តឹងទាមទារតាមមាត្រា២៥ នៃក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច ចុះថ្ងៃទី២៨-១០-១៩៨៨ ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅតិច្ចសន្យា។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៦ ចុះថ្ងៃទី៣១-០៥-២០០៥ របស់ឈ្មោះចម បានប្តឹងមិនសុខចិត្តនឹងដីកាលើកពាក្យបណ្តឹងត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៣៨(ឈ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១-០៥-២០០៥ របស់ឈ្មោះចម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-បដិសេធដីកាលើកពាក្យបណ្តឹងលេខ៤១៧តរ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការព្រះសីហនុ ចោលជាអសារបង់ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោន ៥.០០០៛ និងលើអដ្ឋាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៤-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខៈ៣៨៣ ចុះថ្ងៃទី២៥-០៧-២០០៥ របស់សាលាឧទ្ធរណ៍ទៅតុលាការក្រុងព្រះសីហនុ ដើម្បីចាត់ការដល់អង្គសេចក្តីតាមនីតិវិធី ។

៥-សាលដីកានេះជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១២-០៨-២០០៥ ចំពោះមុខមេធាវីតំណាងគូក្តីនិងមេធាវីតំណាងតតិយជននិងប្រកាសជាសាធារណៈនៅថ្ងៃទី២២-០៨-២០០៥ ចំពោះមុខមេធាវីតំណាងតតិយជនកំបាំងមុខមេធាវីតំណាងគូក្តីតែទុកជាចំពោះមុខ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះលណរ បានប្តឹងមិនសុខចិត្តនឹងសាលដីកា របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សារណារបស់ឈ្មោះលណរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញ សរណាឆ្លើយតបរបស់លោក.................ជាមេធាវីតំណាងឱ្យឈ្មោះឡហហ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញ សារណាធ្វើយតបរបស់លោក.............. ជាមេធាវីតំណាងឱ្យឈ្មោះចម ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

បណ្តឹងសាទុក្ខរបស់ឈ្មោះលណរ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សា ជំនុំជំរះ សម្រេចតាមច្បាប់ ។

ក្រឡាបញ្ជី អានសារណារបស់ឈ្មោះលណរ ។

មេធាវីលោក............. ការពារឱ្យចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា៖

មុនដំបូងខ្លួនសុំឆ្លើយតបនឹងសារណារបស់ចម ដែលលើកឡើងក្នុងសារណាកាលពីថ្ងៃទី៣០-០៦១៩៩៨ ដែលមានកិច្ចសសន្យាវវាងចម និងលណរ ដែលមានការក់ក់ប្រាក់ជាបួនដំណាក់កាល គឺលើកទី១ចំនួនមួយម៉ឺនដុល្លា លើកទី២ កក់ប្រាក់ដប់ភាគរយ ត្រូវជាបួនម៉ឺនប្រាំពាន់ដុល្លាតែលោកចម មិនបានគោរពកិច្ចសន្យាទេ គឺកក់ប្រាក់បានតែ បីប៉ុនប្រាំពាន់ដុល្លា តែប៉ុណ្ណោះ ដោយខ្វះ មួយម៉ឺនដុល្លាទៀនាត់ថា ចាំបង្រ្គប់នៅ ពេលកក់ប្រាក់លើកទី៣ តែតាំងពីពេលនោះមកបាត់មុខលោក ចម រហូតមកដល់ពេលក្រោយទើបមានឈ្មោះ ឡហហ មកអះអាងថា គាត់ជាអ្នកទិញដីនេះទៅវិញ ហើយលើកឡើងថា អ្នកស្រីលណរ បានផ្លាស់ទីលំនៅ នោះគឺជាការមិនត្រឹមត្រូវឡើយ។តាមពិតគឺគាត់ជាអ្នកប្រព្រឹត្តខុស នឹងកិច្ចសន្យាដែលបានព្រមព្រៀងគ្នាមុនទេ។

មេធាវីលោក........... ការពារឱ្យអ្នកស្រីលណរ បានធ្វើសេចក្តីសន្និដ្ឋានថា នេះជារឿងវិវាទកិច្ចសន្យាការទិញ-លក់ដី និងជាកាតព្វកិច្ចរបស់គួភាគីតាំងពីនាក់ ។ មានការកត់ចំណាំ ដូចខាងក្រោម ៖

I- មានកិច្ចសន្យា ចុះថ្ងៃទី៣០-០៦-១៩៩៨ ធ្វើឡើងរវាងអ្នកស្រីលណារ ប្ដីហដស និង ចម និង លោកមុំ ថន ដែលមានការផ្ដិតមេដៃទទួលស្គាល់ទាំងសងខាង ។ តាមការសាវជ្រាវលើសំណុំរឿងមក គឺលោកចម បង្កើតជាកំហុសឡើងដែលមានចំណុចគួរឱ្យសំគាល់ដូចខាងក្រោម៖

១/មិនបានគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នាទេ ។

២/ហេតុអ្វីបានជាកម្មសិទ្ធិ ដែលមិនទាន់បានផ្ទេរសិទ្ធិត្រឹមត្រូវផងគាត់ហ៊ានយកដីនេះទៅលក់ឱ្យលោកឡហហ ទៅវិញ នេះគឺជាការលួចលក់ដីរបស់អ្នកដទៃ ។

៣/ បើនិយាយអំពីអាជ្ញាយុកាល គឺត្រូវហួសអាជ្ញាយុកាលតាមច្បាប់កំណត់ហើយ ។

II-កិច្ចសន្យា ចុះថ្ងៃទី៣០-០៦-១៩៩៨ ការលក់នេះមានកម្មវត្ថុត្រឹមត្រូវជាក់លាក់ដីនោះមានប្លង់ដល់ទៅបីគឺ $A_1$៣៥៤$A_4$ ៣៥៥,$A_1$៣៥៦ ដែលមានឈ្មោះនៅក្នុងកម្មសិទ្ធិទាំងអស់ជានរួមគ្នាលក់ ហើយបានប្រគល់ សិទ្ធិឱ្យអ្នកស្រីលណារ ធ្វើជាកិច្ចសន្យាដើម្បីលក់ដីទាំងអស់នេះ ដែលមានមេធាវីទទួលស្គាល់ផងដែរ ។

III- កាតព្វកិច្ចកិច្ចសន្យាតាមមាត្រា២២ក្រឹត្យ-ច្បាប់លេខ:៣៨ បញ្ជាក់ថា កិច្ចសន្យាជាច្បាប់របស់គូភាគីតាមកិច្ចព្រមព្រៀងគ្នាមានការបង់ប្រាក់ជាបួនដំណាក់កាលទី១ បង់មួយម៉ឺនដុល្លា ទី២បង់១០% ស្មើទឹកប្រាក់ចំនួនបួនម៉ឺនប្រាំពាន់ដុល្លា តែលោកចម បានបង់លើកទី២នេះមិនគោរពតាមក្កិសន្យាឡើយ គឺនៅខ្វះ មួយម៉ឺនដុល្លា ទៀត លើកទី៣២៥ ទៀត តែដោយលើកទី២ ចំពោះប្រាក់ដែលនៅខ្វះគាត់ចាំបង្រ្គាប់ នៅដំណាក់ កាលទី៣ តាំងពីពេលនោះមកក៏បាត់មុខគាត់រហូត ទើបលេចចេញលោក ឡហហ មកអះអាងថា គាត់ទើបជាអ្នកទិញ ដីពិតប្រាកដតែនៅក្នុងកិច្ចសន្យាមិនមានឈ្មោះ ឡហេងហួតទេ ហេតុអ្វីបានជាគាត់ហ៊ានមកចង់លុយជំនួសឈ្មោះ ចម ទៅវិញ? ។

តាមច្បាប់ និងតាមយុត្តិធម៌លោកឡហហ ត្រូវប្ដឹងលោកចម ទើបជាការត្រឹមត្រូវ ព្រោះ៖លោកចម គាត់យកដីរបស់គេទៅលក់ ហើយបានទទួលប្រាក់ពីលោក ឡហហ ចំណែកកូនក្ដីរបស់ខ្លួនមិន ពាក់ពន្ធ័ជាមួយលោកឡហហទេ ។

IV- ការបន្តកិច្ចសន្យាតាមហេតុផលត្រូវផុតអាជ្ញាយុកាលអស់ហើយ ដូចជាមិនបានគោរពតាមកិច្ចសន្យា តាំងពីបង់ប្រាក់កក់នៅដំណាក់កាលទី២ មកម្ល៉េះ ។ តាមការប្ដឹងរបស់ភាគីទាំងពីរនោះឃើញថាមានរយៈពេលដល់ ទៅប្រាំពីរឆ្នាំដូចគ្នា ដូច្នេះកិច្ចសន្យានេះត្រូវបានហួសអាជ្ញាយុកាលដូចគ្នា ។

ការអវត្តមានលោកហ្គោ ដេសៀត តែប្រពន្ធរបស់គាត់អ្នកស្រីលណារ មានអាស្រ័យដ្ឋានច្បាស់លាស់ ដូច្នេះការលើកពីអវត្តមាននេះគឺ មិនត្រឹមត្រូវឡើយ ហើយគាត់ថា : បានប្ដឹងPM ដើម្បីទប់ស្កាត់ការផ្ទេរសិទ្ធិដីធ្លី នេះក៏ជាការមិនត្រឹមត្រូវដែរ ។

ដូច្នេះ សរុបសេចក្ដីមកខ្លួបដិសេធ សាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងមូល។ដោយសុំតម្កល់ដីកា លើកពាក្យបណ្ដឹង របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការវិញ ។

មេធាវីលោក................ការពារឱ្យលោកចម បានធ្វើសេចក្ដីសន្និដ្ឋានថា:

កាលពីថ្ងៃទី៣០-០៦-៩៨ កូនក្ដីខ្លួនបានធ្វើកិច្ចសន្យាទិញដីទំហំ ដប់ហិកតាហាសិបអា រវាងអ្នកស្រីលណារ និងហជសដែលបានសន្យាអនុវត្តជាបួនដំណាក់កាល កូនក្ដីរបស់ខ្លួនបានអនុវត្តត្រឹមត្រូវហើយ នៅថ្ងៃទី២៣-០៧-១៩៩៨ ដោយជួសមុខឱ្យលោកឡហហ បានប្រគល់ប្រាក់ចំនួនបីម៉ឺនប្រាំពាន់ដុល្លា ឱ្យឈ្មោះលណារ និងលោក ហជស ដោយមានទាំងផ្ដិតមេដៃលើកិច្ចសន្យាទទួលប្រាក់ជាភស្ដុតាងទៀតផង ។

នៅថ្ងៃទី២៦-០៨-៩៨ ដែលត្រូវប្រគល់លុយនៅដំណាក់កាលទី២ឈ្មោះឡហហ បានយកប្រាក់ចំនួនបីម៉ឺនដុល្លា ឱ្យទៅឈ្មោះហជស និងលណារ ដោយផ្ទាល់ព្រមទាំងបានចុះហត្ថលេខាទទួលប្រាក់ទៀតផង លុះដល់ថ្ងៃកំណត់ទី១៥-០៩-៩៨ ជាថ្ងៃប្រគល់ប្រាក់គ្រប់ចំនួនឈ្មោះលណារ និងលោកហជសបានតិចខ្លួនបាត់មិនព្រមមកអនុវត្តតាមកិច្ចសន្យានេះទេ ។

កូនក្ដីរបស់ខ្លួនបានទៅឃ្លាំមើលដីនោះរហូតខ្លាចមានការផ្ទេរកម្មសិទ្ធិ ដោយខ្លាចទប់ស្កាត់មិនបានកូនក្ដីរបស់ខ្លួនបានប្ដឹងទៅPM ដើម្បីជួយទប់ស្កាត់ ។

សំណូមពរ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

មេធាវីលោក.................ការពារឱ្យលោកឡហហ បានធ្វើសេចក្ដីសន្និដ្ឋានថាៈ

លោក ឡហេងហួត បានទិញដីពីលោកចម ដែលមានប្លង់ដីលេខៈ $A_1$៣៥៤$A_4$ ៣៥៥,$A_1$៣៥៦ និង$A_1$៣៥៦ ហើយបានប្រគល់ប្រាក់ចំនួនបួនម៉ឺនប្រាំពាន់ដុល្លាអាមេរិក ឱ្យទៅលោកចម ដោយផ្ទាល់ និងបានកក់ប្រាក់ ជាបន្តបន្ទាប់ទៅឱ្យលោកចម សរុប ប្រាំពីរម៉ឺនប្រាំពាន់ដុល្លាអាមេរិក។ នៅថ្ងៃចុងក្រោយដែលត្រូវបង់បង្គ្រប់លោកហជស ក៏បានគេចខ្លួនរហូតមក ម្ដងថានៅចិន ម្ដងជានៅសាំងហ្គាព័រ នេះសបញ្ជាក់ឱ្យឃើញថាលោក ហជស មានចេតនាគេចខ្លួនតែម្ដង ។ យោងតាមក្រឹត្យ-ច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៩៨ នៃ មាត្រា២៦ ចែងថា អាជ្ញាយុកាលត្រូវផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅដ្ឋាន ហើយអវត្តមាននេះ ត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ។ លោក ចម និងលណារ ជាអ្នកគួកជេរទេ ពាក្យថា លណារ ជាអ្នកទទួលសិទ្ធិតាមច្បាប់នោះជាការមិនត្រឹមត្រូវទេគឺគាត់គ្រាន់តែជាសាក្សីប៉ុណ្ណោះ ។

សំណូមពរ សុំតម្កល់សាលដីកាលេខ១៣៨(ឈ) ចុះថ្ងៃទី២២-០៨-២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សារណា របស់អ្នកស្រី លណារ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីនៃគូភាគី និងតតិយជន

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា ៖ បណ្តឹងសាទុក្ខលេខៈ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់លោកលណារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានដោយយោងតាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា : ការដែលមេធាវីចុងចម្លើយលើកឡើងថា ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធន៍ដីកា លើកពាក្យបណ្តឹងលេខៈ៤១៧ តរ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការក្រុងកំពង់សោម អសារបង់ជាការភន្ត័ច្រឡំ ដោយហេតុថា កិច្ចសន្យាចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ ហួសអាជ្ញាយុកាល ហើយសុំឱ្យ តុលាការកំពូល តម្កល់ដីកាលើកពាក្យបណ្តឹង របស់តុលាការក្រុងព្រះសីហនុនោះជាការពុំត្រឹមត្រូវទេ ព្រោះថា តុលាការក្រុងព្រះសីហនុ បានសម្រេចលើកពាក្យបណ្តឹងរបស់ដើមចោទចោលតាមដីកា ដោយមិនបានកោះហៅគូភាគី ឱ្យចូលរួមឡើយ ។

យល់ឃើញថា គូភាគីនៃរឿងក្តីនេះ ពុំបានចូលរួមសវនាការនេះទេ តែមេធាវីរបស់គូភាគីបានចូលរួម ដូចនេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែបាត់ទុកជាចំពោះមុខ។

យល់ឃើញថា សាលក្រមរដ្ឋប្បវេណីលេខ១៣៨(ឈ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីកំបាំងមុខដើមចោទចុងចម្លើយ និង តតយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់អ្នកស្រីលណារ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៣៨(ឈ) ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខៈ៤១៩ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ទៅតុលាការក្រុងព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធី ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលចុងចម្លើយ បានបង់គឺ

- ពុទ្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៨,០០០៛ ។

៥ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៦ ខែមករាឆ្នាំ២០០៦។